ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 11 / 2008
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច

ដាក់ទៅ: សហចៅក្រមស៊ើបអង្កេត

ថ្ងៃដាក់: ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ភាគីអ្នកដាក់: សហមេធាវីរបស់លោក អៀង សារី

ភាសាដើម: អង់គ្លេស

ប្រភេទឯកសារ: សាធារណៈ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

## សំណើរបស់លោក អៀង សារី សុំបន្ថែមចំនួនទំព័រដែលបានកំណត់ ដើម្បីដាក់សេចក្តីសង្កេតបន្ថែមស្តីពីការអនុវត្តន៍ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌបែប សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក

---

**<u>អ្នកដាក់ឯកសារ៖</u>**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>អ្នកទទួលឯកសារ៖</u>**

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (ហៅកាត់ថា "មេធាវីការពារក្តី") អនុលោមទៅតាម មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[1] សូមស្នើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ដើម្បីដាក់សេចក្តីសង្កេតបន្ថែមស្តីពី ការអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌបែបសហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ក.ត ដោយអនុលោមទៅតាមដីកាសម្រេចលើពាក្យសុំរបស់សហចៅក្រមស៊ើបអង្កេត (ហៅកាត់ថា "ក.ស.ច.ស") ចុះថ្ងៃទី ១៦ កញ្ញា ២០០៨[2] ។ មេធាវីការពារក្តី ក៏សូមស្នើដោយក្តីគោរពផងដែរថា ក.ស.ច.ស សូមទទួលយកនូវសេចក្តីសន្និដ្ឋានបន្ថែមដ៏មានខ្លឹមសារនានារបស់លោក **អៀង សារី** ស្តីពីបញ្ហានេះដែលសេចក្តីទាំងនោះត្រូវបានភ្ជាប់ជូនមកជាមួយជាឧបសម្ព័ន្ធនឹងសំណើសុំនេះ ។

1. មេធាវីការពារក្តីបានដាក់នូវសេចក្តីជំទាស់នឹងការអនុវត្តនូវ ការទទួលខុសត្រូវព្រហ្មទណ្ឌបែបសហកម្មឧក្រិដ្ឋកម្មរួម (ហៅកាត់ថា "JCE") នៅ អ.វ.ក.ត កាលពីថ្ងៃទី ២៨ កក្កដា ២០០៨ [3]។ ចម្លើយតបនឹងសេចក្តីជំទាស់នេះត្រូវបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា (ហៅកាត់ថា "ក.ស.ព") កាលពីថ្ងៃទី ១១ សីហា ២០០៨ [4]។ ដោយទទួលស្គាល់នូវសារសំខាន់នៃបញ្ហានេះ និងផលប៉ះពាល់របស់វាមកលើជនត្រូវចោទទាំងអស់ ក.ស.ច.ស បានស្នើអោយមានការដាក់សេចក្តីសន្និដ្ឋានបន្ថែមនានាស្តីពីបញ្ហានេះពីគ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២ អោយបានមុនថ្ងៃទី ៣១ ធ្នូ ២០០៨ [5]។

2. ដំណាលគ្នានេះ ក.ស.ព បានធ្វើបណ្តឹងឧទ្ធរណ៍នឹងការបដិសេធ JCE នៅក្នុងដីកាសម្រេចបញ្ជូនរឿងទៅជម្រះដែលចេញដោយ ក.ស.ច.ស នៅក្នុងរឿងក្តី កាំង ហ្កេកអ៊ាវ "ឌុច" [6] ។ នៅក្នុង

---

[1] *អវតក/០១/២០០៧/វិ.៣* ៨ តុលា ២០០៨ ។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១៦ កញ្ញា ២០០៨ (ហៅកាត់ថា "ដីកាសម្រេចលើពាក្យសុំ")។

[3] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ពាក្យសុំរបស់លោក អៀង សារីប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២៨ កក្កដា ២០០៨ ។

[4] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់ អៀង សារី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១១ សីហា ២០០៨ ។

[5] ដីកាសម្រេចលើពាក្យសុំ ទំព័រ ២ ។

[6] *ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២) បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ធ្វើនៅថ្ងៃទី ៥ កញ្ញា ២០០៨ (ហៅកាត់ថា "បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព") ។

បណ្តឹងឧទ្ធរណ៍នោះ អង្គបុរេជំនុំជម្រះ បានស្នើអោយមានការដាក់សារណានានាស្តីពីការអនុវត្តនូវ JCE នៅ អ.វ.ក.ត ក្នុងរវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែលត្រូវដាក់ដោយ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ចំនួនបី [7] បន្ថែមពីលើសេចក្តីសន្និដ្ឋាននានារបស់ ក.ស.ព និង មេធាវីការពារក្តី និង ភាគីរដ្ឋប្បវេណី ។ សារណាចំនួនបីរបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ត្រូវបានដាក់ដោយអនុលោមទៅតាមសេចក្តីអញ្ជើញរបស់ អង្គបុរេជំនុំជម្រះ ហើយមានទំហំស្មើនឹង ៩៧ ទំព័រ នៃអំណះអំណាងទៅលើបញ្ហានេះ [8] ។ សារណានីមួយៗបានបកស្រាយនូវបញ្ហាដែលមានទិដ្ឋភាពផ្សេងគ្នា និងបានបកស្រាយបញ្ហាដែលមិនបានលើកឡើងដោយមេធាវីការពារក្តី និង ក.ស.ព នៅក្នុងសារណានានាដែលបានដាក់ជូនចំពោះមុខ ក.ស.ច.ស ។

3. ដើម្បីឆ្លើយតបអោយបានគ្រប់គ្រាន់ទៅលើបញ្ហានេះ ដែលមានផ្ទុកនៅក្នុងសារណានានាដែលដាក់ដោយ*អ្នកមិនមែនជាភាគីនៃរឿងក្តី* មេធាវីការពារក្តីសូមស្នើដោយក្តីគោរពសូមអោយមានការបន្ថែមចំនួនទំព័រ ពី ១៥ ទៅ ៣០ ទំព័រនៃចំនួនទំព័រដែលបានកំណត់សំរាប់ការដាក់ឯកសារជូនចំពោះមុខ ក.ស.ច.ស ។ ការបន្ថែមទំព័របែបនេះ នឹងធ្វើអោយបញ្ហានេះនឹងត្រូវបានសិក្សាស្រាវជ្រាវដោយគ្រប់គ្រាន់ពីទស្សនវិស័យរបស់មេធាវីការពារក្តី ។ វាក៏នឹងមិនបង្កអោយមានការខូចខាតដល់ ក.ស.ព និងភាគីរដ្ឋប្បវេណីនានាឡើយ ។ ជាការពិត មេធាវីការពារក្តីមិនជំទាស់នឹងការបន្ថែមចំនួនទំព័រស្រដៀងគ្នានេះ ចំពោះសេចក្តីសន្និដ្ឋានបន្ថែមនានារបស់ភាគីនានាឡើយ។

4. ម្យ៉ាងទៀត ជាផលប្រយោជន៍ខាងសេដ្ឋកិច្ចរបស់តុលាការ ហើយក៏ដើម្បីជួយផងដែរដល់ ក.ស.ច.ស ក្នុងការផ្ទៀងផ្ទាត់នូវភាពចាំបាច់អោយមានការបន្ថែមនូវចំនួនដែលបានកំណត់សំរាប់ការដាក់សេចក្តីសង្កេតបន្ថែមនានាស្តីពី JCE មេធាវីការពារក្តីបានភ្ជាប់មកជាមួយនូវសេចក្តីសង្កេត

---

[7] *ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២) សេចក្តីអញ្ជើញអោយដាក់សារណានៃ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ២៣ កញ្ញា ២០០៨ និង *ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២) សេចក្តីអញ្ជើញអោយដាក់សារណានៃ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ។

[8] ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក (អបជ០២) សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី*របស់សាស្ត្រាចារ្យ Antonio Cassese និង សមាជិកនៃវិទ្យាស្ថានបុរ្សគ្គិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិស្តីពីទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ។ សារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី*ទាក់ទងនឹងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក (អបជ០២) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ (សារណាដែលដាក់ដោយសាស្ត្រាចារ្យ Kai Ambos) ។ សារណាដាក់ដោយមជ្ឈមណ្ឌលសម្រាប់សិទ្ធិមនុស្សនិងពហុនិយមនៃសកលវិទ្យាល័យ McGill ម៉ុងត្រេអាល កាណាដា ។

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

បន្ថែមជាឧបសម្ព័ន្ធនឹងឯកសារនេះ។ ហេតុដូច្នេះ បើសិនជាសំណើសុំអោយមានការបន្ថែមនូវចំនួនទំព័រដែលបានកំណត់ត្រូវបានអនុញ្ញាត សេចក្តីសន្និដ្ឋាននានាដែលបានភ្ជាប់មកជាមួយនេះនឹងត្រូវក្លាយជា សេចក្តីសង្កេតបន្ថែមនានារបស់លោក **អៀង សារី** ដូចបានស្នើសុំដោយ ក.ស.ច.ស ។

**អាស្រ័យដោយ**មូលហេតុដូចបានលើកឡើងនៅទីនេះ មេធាវីការពារសូមស្នើសុំដោយក្តីគោរពដល់សហចៅក្រមស៊ើបអង្កេត មេត្តា៖

ក. **អនុញ្ញាត** តាមសំណើសុំអោយបន្ថែមចំនួនទំព័រដែលបានកំណត់ពី ១៥ ទៅ ៣០ ទំព័រ សំរាប់សេចក្តីសង្កេតបន្ថែមនានាស្តីពី ដែលបានអនុញ្ញាតដោយដីកាសម្រេចចុះថ្ងៃទី ១៦ កញ្ញា ២០០៨

ខ. **ទទួលយក** សេចក្តីសន្និដ្ឋាននានាដែលដាក់ភ្ជាប់ជាឧបសម្ព័ន្ធនឹងសំណើសុំនេះថាជាសេចក្តីសង្កេតបន្ថែមនានាស្តីពីការអនុវត្តន៍សហកម្មឧក្រិដ្ឋរួមនៅ អ.វ.ក.ត និង

គ. **ប្រកាសថា** រាល់ទម្រង់ទាំងបីនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌតាមបែបសហកម្មឧក្រិដ្ឋកម្មរួម ទាំងអស់នេះមិនមែនជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៤ ខែវិច្ឆកា ឆ្នាំ ២០០៨**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**